សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៥១៩ "ជ"
-ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៩
-សំណុំរឿងព្រហ្មទណ្ឌលេខ: ៣១៣៤
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨
-សំណុំរឿងស៊ើបសួរលេខ: ១៧៨៩
ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨
-សំណុំរឿងជំនុំជំរះលេខ: ៣៣៩១
ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាខនាមប្រជារាស្ត្រខ្មែរ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៩ វេលាម៉ោង ០៨និង០០ នាទី នៅសាលសវនាការទី ២ ដោយមានសមាសភាព៖

ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមជំនុំជម្រះ

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣១៣៤ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៨ ដែលមាន:

-ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា ភេទប្រុស អាយុ៣៥ឆ្នាំ មុខរបរកសិ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កើត [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅបន្ទប់លេខ១ ផ្លូវលំ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុផល "រ" ម្តាយឈ្មោះ [redacted] សៀងឌី "រ" ប្រពន្ធឈ្មោះ [redacted] ជាន់ឌី ហៅ អេឡិច "រ" មានកូនចំនួន ០១នាក់ ទោសពីមុន "គ្មាន" ជាទីតិជន ។

-មានខ្លឹន: ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៤១៥០ "រ"ដ.ឃ.ដ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ១ ផ្លូវលំ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ដោយមានលោក [redacted] មានការិយាល័យផ្ទះលេខ ៣៦អឺ០ ផ្លូវលេខ ៩៩ ក្រុម៦ ភូមិ៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារ ។

-បានឃើញរបាយការណ៍បញ្ជូនលេខ ៧៨០ រ.ប.ក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៨ របស់មន្ទីរប្រឆាំងគ្រឿងញៀន ។

-បានឃើញដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរលេខ ១៧៩៨ អ.ឃ.ភ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ ៣៣៨៧ អ.ឃ.ភ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៤៦១៧ "ថ"ដ.ដ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

អង្គហេតុដែលបណ្តាលឲ្យមានការចោទប្រកាន់មានដូចតទៅ

-តាមដីកាសន្និដ្ឋានស្តាពរលេខ ៣៣៨៧ អ.ឃ.ភ ចុះថ្ងៃទី ខែសីហា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា: កាលពីថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៨ វេលាម៉ោង ១៦និង៣០នាទី ដោយមានការ

សម្របសម្រួលពីតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ កម្លាំងការិយាល័យនីតិវិធីនៃមន្ទីរប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀននៅចំណុចបន្ទប់លេខ១ ផ្លូវលំ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ ពេលសមត្ថកិច្ចចូលទៅដល់ជនជាប់ចោទខាងលើមានការភ័យស្លន់ស្លោបំរុងរត់គេចខ្លួន ហើយក៏រអិលជើងដួលមកក្រោយមុតកាំបិតផ្តាក់ដែលជនសង្ស័យរក្សាទុកក្នុងបន្ទប់ បណ្តាលឲ្យរបួសមុតកញ្ឆឹងកផ្នែកខាងក្រោយ ។ ក្រោយមកសមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួនជនសង្ស័យខាងលើរួមទាំងវត្ថុតាងនាំមកសាកសួរនៅមន្ទីរប្រឆាំងគ្រឿងញៀន ។ ក្រោយពីសាកសួររួចជនជាប់ចោទខាងលើបានឆ្លើយសារភាពថា: ចំពោះថ្នាំញៀនដែលសមត្ថកិច្ចធ្វើការដកហូតបានខាងលើគឺឈ្មោះ ជ្រុយ ភេទប្រុស អាយុប្រហែល៣៧ឆ្នាំ ជាអ្នកយកមកអោយខ្លួនលក់បន្តអោយម៉ូយ ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា បានឆ្លើយថា: ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនម៉ាទឹកកកតាំងពីឆ្នាំ ២០១០ ហើយខ្លួនត្រូវបានម្តាយបញ្ជូនទៅមណ្ឌលអប់រំកែប្រែបន្សាបគ្រឿងញៀនចំនួន ០២លើក ។ រហូតដល់ឆ្នាំ ២០១៨ ខ្លួនក៏ចំនាក់ចំនងជាមួយឈ្មោះ [redacted] ភេទប្រុស ជាអ្នកលក់គ្រឿងញៀននៅម្តុំស្ទឹងមានជ័យ និងបានទិញគ្រឿងញៀនពីឈ្មោះ ជ្រុយ យកមកប្រើប្រាស់ក្នុងតម្លៃ ២០.០០០(ពីរម៉ឺន)រៀល ។ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ ឈ្មោះ ជ្រុយ បានយកគ្រឿងញៀនប្រភេទក្រាមពណ៌សថ្លាទម្ងន់ ០១ដឺ និងថង់ប្លាស្ទិកសថ្លាតូចៗមួយចំនួនមកឲ្យខ្លួនរក្សាទុកក្នុងបន្ទប់ និងជញ្ជីងអេឡិចត្រូនិច០១ ទុកសម្រាប់ថ្លឹងពេលម៉ូយកម្មង់ទិញ ។ ពេលមានម៉ូយមករកទិញខ្លួនទូរស័ព្ទទៅប្រាប់ឈ្មោះ ជ្រុយ ហើយឈ្មោះ ជ្រុយ នឹងមកចាត់ចែងវិលែកគ្រឿងញៀនលក់ឲ្យម៉ូយដោយខ្លួនឯង នៅសល់បន្តិចបន្តួចឈ្មោះ ជ្រុយ ទុកឲ្យខ្លួនប្រើប្រាស់ ។ លុះមកដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨ ឈ្មោះ ជ្រុយ បានយកគ្រឿងញៀនមកប្រគល់ឲ្យខ្លួនរក្សាទុកលក់ដូចសព្វដង ។ រហូតដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង ១៥និង០០នាទីជាង មានបុរសនិងស្ត្រី ០២នាក់ បានមកសួរនាំរកទិញគ្រឿងញៀននៅបន្ទប់របស់ខ្លួនក្នុងតម្លៃ ៥០ (ហាសិប) ដុល្លារអាមេរិក ពេលនោះខ្លួនបានទូរស័ព្ទទៅប្រាប់ឈ្មោះ ជ្រុយ ថាមានម៉ូយរកទិញគ្រឿងញៀនហើយឈ្មោះ ជ្រុយ បានឲ្យខ្លួនវិលែកគ្រឿងញៀនជាពីរកូនថង់តូចលក់ឲ្យគេ ពេលខ្លួនកំពុងធ្វើសកម្មភាពដោះដូរគ្រឿងញៀននៅក្នុងបន្ទប់ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

-ក្រឡាបញ្ជីបានអានរបាយការណ៍ និងលិខិតព័ត៌មានរបស់មន្ត្រីនគរបាលយុត្តិធម៌ របាយការណ៍សំយោគកំណត់ហេតុពិនិត្យកន្លែងកើតហេតុបញ្ជាក់ថា: ករណីនេះជាករណីរក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

ក.ជនសង្ស័យឈ្មោះ [redacted] វឌ្ឍនា ភេទប្រុស គឺពិតជាបានប្រព្រឹត្តបទល្មើស រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន ។

ខ.ឈ្មោះ ជ្រុយ ភេទប្រុស អាយុប្រហែល ៣៧ឆ្នាំ កម្ពស់ប្រហែលមួយម៉ែត្រចិតសិបប្រាំ សក់វែង សម្បុរសគឺជាមេខ្លោងជួញដូរគ្រឿងញៀនដោយខុសច្បាប់ក្នុងករណីនេះ ។

ចំណែកឈ្មោះ [redacted] ផាន់ធី មិនពាក់ព័ន្ធក្នុងករណីរក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនទេ គឺគ្រាន់តែបានប្រើប្រាស់បំពាន (មិនរៀងចាល) ដោយខុសច្បាប់នូវសារធាតុញៀន ។

-ក្រឡាបញ្ជីបានអានកំណត់ហេតុទទួលវត្ថុតាងចាប់យកលេខ ១៥១០ រ.វ.ត ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ បានពិនិត្យភិនភាគវត្ថុចាប់យកដែលទាក់ទិនក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៣១៣៤ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា ភេទប្រុស អាយុ៣៥ឆ្នាំ រួមមាន:

ក.ស្រោមសំបុត្រពណ៌លឿងទុំ មានបោះត្រា បិទជិត ចំនួនមួយ មានផ្ទៃពង្គៀរដែរបស់ជនសង្ស័យឈ្មោះ [redacted] វឌ្ឍនា ដោយមានចុះហត្ថលេខារបស់អ្នកចូលរួមសរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀនប្រភេទម្សៅក្រាមពណ៌សថ្លា ទម្ងន់សរុប ៨,៣១ (ប្រាំបីក្បៀសសាមសិបមួយ) ក្រាម ។

ខ.ជញ្ជីងអេឡិចត្រូនិចសម្រាប់ថ្លឹងគ្រឿងញៀនចំនួនមួយគ្រឿង ។

គ.ឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយកំប្លេ និងថង់វិចខ្ចប់គ្រឿងញៀនចំនួនមួយ ។

ឃ.កាំបិតផ្តាក់ចំនួន ០២ (ពីរ) ដើម ។

-ក្រឡាបញ្ជីបានអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៤៨៩១ /១៨ ម.ព.អ.ជ.ប.ត.ញ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ បញ្ជាក់ថា: សំណាកគ្រឿងញៀនប្រភេទម្សៅឈ្មោះ **មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក)** , ដែលមានកម្រិតភាពសុទ្ធ ៧៨.៣០% នៃទម្ងន់សរុប , **វាស្ថិតនៅ តារាងទី២ មាត្រា៥** ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

តាមដីកាសន្និដ្ឋានស្តាពរលេខ ៣៣៨៧ អ.យ.ភ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចប្តឹងទៅចៅក្រមជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted] **វឌ្ឍនា** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមមាត្រា ៤០ នៃ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការឃើញថាជនជាប់ចោទឈ្មោះ [redacted] **វឌ្ឍនា** បានសារភាពទោសកំហុសរបស់ខ្លួនថា ពិតជាបានជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ហេតុដូច្នេះតំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្តាពរលេខ ៣៣៨៧ អ.យ.ភ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូង រាជធានីភ្នំពេញ និងប្តឹងទៅលោកចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា បានសន្និដ្ឋានថា:

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទសូមធ្វើសេចក្តីសន្និដ្ឋានការពារជូនលោកចៅក្រមជំនុំជម្រះ អំពីដំណើររឿងអង្គហេតុនិងអង្គច្បាប់ដូចខាងក្រោមនេះ៖

១-ដំណើររឿង

កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ កូនក្តីរបស់នាងខ្ញុំ [redacted] **វឌ្ឍនា** បានទទួលគ្រឿងញៀនដែលជារបស់ឈ្មោះ ជ្រុយ ដើម្បីទុកប្រើប្រាស់ជាមួយឈ្មោះ ជ្រុយ នេះ ដែលជាគ្រឿងញៀនក្រាមពណ៌សថ្លា ទម្ងន់ ០១ដឺ ។ ហើយជញ្ជីងអេឡិចត្រូនិច ០១ គឺឈ្មោះ ជ្រុយ បានយកមកផ្ញើជាមួយកូនក្តីរបស់នាងខ្ញុំសិនចាំមួយថ្ងៃពីរខ្លួនមកយកវិញ ។ ប៉ុន្តែបានប៉ុន្មានថ្ងៃក្រោយមកមិនឃើញឈ្មោះ ជ្រុយ មកយកជញ្ជីងវិញទេ ។ នៅក្នុងអំឡុងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង ១៤ជាង មានបុរសម្នាក់ និងស្ត្រីម្នាក់ ដែលឈ្មោះ ជ្រុយ បានណែនាំឲ្យមកផ្ទះរបស់កូនក្តីនាងខ្ញុំសិន ទើបខ្លួនមកជួបតាមក្រោយ បានបន្តិចក្រោយមកឈ្មោះ ជ្រុយ បានមកជួបជាមួយបុរស និងស្ត្រីម្នាក់នោះ ហើយបុរស និងស្ត្រីដែលមិនស្គាល់ឈ្មោះនោះបានសួរទៅឈ្មោះ ជ្រុយ ថាមានគ្រឿងញៀនសម្រាប់លក់ ឬអត់ ? ហើយឈ្មោះ ជ្រុយ បានប្រាប់ថាមាន នៅពេលនោះដែលឈ្មោះ ជ្រុយ បានយកគ្រឿងញៀនមកចែកឲ្យបុរស និងស្ត្រីដែលមិនស្គាល់ឈ្មោះនោះចំនួន ៥០(ហាសិប)អុណ្ឌារអាមេរិក នៅពេលដែលកំពុងតែប្រគល់គ្រឿងញៀន ស្រាប់តែមានសមត្ថកិច្ចចុះមកបង្ក្រាប ប៉ុន្តែឈ្មោះ ជ្រុយ បានរត់គេចខ្លួនបាត់ទៅឃើញដូច្នេះ កូនក្តីនាងខ្ញុំមានការភ័យខ្លាចក៏បំរុងនឹងរត់ស្រាប់តែរអិលជើងដួលមុតនឹងកាំបិតដែលធ្វើឲ្យមានរបួសត្រង់កញ្ចឹងក ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

២-អង្គហេតុ

នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ១៤ជាង កូនក្តីនាងខ្ញុំកំពុងតែនៅបន្តប់ជួល ស្រាប់តែមានសមត្ថកិច្ចបានធ្វើការឃាត់ខ្លួន និងបាននាំខ្លួននៅចំណុចបន្តប់ជួលលេខ ០១ ផ្លូវលំ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ តែម្តង ។

៣-អង្គច្បាប់

តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញធ្វើការចោទប្រកាន់កូនក្តីរបស់នាងខ្ញុំឈ្មោះ [redacted] វឌ្ឍនា ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

សេចក្តីសន្និដ្ឋាន

យោងតាមអង្គហេតុ និងអង្គច្បាប់ខាងលើ ឃើញថានៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ សមត្ថកិច្ចពិតជាបានដកហូតថ្នាំញៀន និងជញ្ជីងថ្លឹងនេះមិនមែនជារបស់កូនក្តីនាងខ្ញុំទេ តាមការពិតគឺរបស់ឈ្មោះ ជ្រុយ ដែលគេយកមកផ្ញើទុកពីរបីថ្ងៃតែប៉ុណ្ណោះ ហើយកូនក្តីនាងខ្ញុំមិនបានប្រព្រឹត្តអំពើជួញដូរគ្រឿងញៀនអ្វីចតាមការចោទប្រកាន់នោះទេ ។ ជាក់ស្តែងនៅថ្ងៃកើតហេតុគឺឈ្មោះ ជ្រុយ ដែលជាម្ចាស់គ្រឿងញៀនបាននាំមនុស្សប្រុសស្រីពីរនាក់ទៅទិញថ្នាំញៀននៅបន្ទប់ជួលរបស់កូនក្តីនាងខ្ញុំហើយនៅពេលនោះមិនទាន់ទិញផង ក៏ត្រូវបានសមត្ថកិច្ចមកដល់បានធ្វើការឆែកឆេរនៅក្នុងបន្ទប់ជួលក៏បានឃើញថ្នាំញៀន ក៏បានឃាត់ខ្លួនកូនក្តីនាងខ្ញុំតែម្តង ចំណែកឈ្មោះ ជ្រុយ ក៏រត់គេចខ្លួនបាត់ ។ ក្នុងរឿងនេះឃើញថាកូនក្តីរបស់នាងខ្ញុំមិនមែនជាបុគ្គលចំបងដែលចេញមុខលក់ដូរនោះទេ គឺកូនក្តីនាងខ្ញុំគាត់ធ្វើតាមបង្គាប់បញ្ជារបស់ឈ្មោះ ជ្រុយ ដើម្បីបានគ្រឿងញៀនយកមកជក់ខ្លះ មិនចាំបាច់ចំណាយប្រាក់តែប៉ុណ្ណោះ ។

ហេតុដូច្នេះសំណូមពរ

សូមលោកចៅក្រមជំនុំជម្រះមេត្តាពិនិត្យ និងសម្រេចឲ្យកូនក្តីរបស់នាងខ្ញុំឈ្មោះ [redacted] វឌ្ឍនា ទទួលបានទៅស្ថានសម្រាលទោសទៅតាមមាត្រា១៦៥ នៃក្រមព្រហ្មទណ្ឌ ដើម្បីឲ្យកូនក្តីរបស់យើងខ្ញុំឆាប់បានវិលត្រឡប់ ទៅជួបគ្រួសារ និងបានបន្តការសិក្សាបន្ថែមទៀត និងមានឱកាសកែខ្លួនធ្វើជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គមវិញ ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូមលោកចៅក្រមជំនុំជម្រះ មេត្តាពិនិត្យ និងទទួលតាមសំណូមពរបស់នាងខ្ញុំ ដោយក្តីអនុគ្រោះ ។

-ជនជាប់ចោទបានឱឡាយសម្តីចុងក្រោយថា: សូមតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សម្តីចុងក្រោយជនជាប់ចោទ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សាលាដំបូងរាជធានីភ្នំពេញ
យល់ឃើញថា

១-តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៣៨៧ អ.យ.ភ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាសម្រេចបញ្ជូនរឿងទៅជម្រះលេខ ៤១៦ "ច"អ.ដ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៨ របស់ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា ទៅជម្រះពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ១ ផ្លូវលំ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា មានភាពស៊ីសង្វាក់គ្នាទៅនឹងការចាប់ឃាត់ខ្លួនរបស់សមត្ថកិច្ច នៅទីឯកន្លែងកើតហេតុព្រមទាំងដកហូតបានថ្នាំញៀនសរុបចំនួន ៨,៣១(ប្រាំបីក្បៀសសាមសិបមួយ) ក្រាម ។ ចម្លើយ

នេះអាចឱ្យតុលាការជឿបានថាជនជាប់ចោទពិតជាបាន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលច្បាប់តម្រូវឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-តាមចម្លើយជនជាប់ចោទ និងរបាយការណ៍សំយោគលេខ ៧៨០ រ.ប.ក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ បានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់ជួលលេខ១ ផ្លូវលំ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ប្រាកដមែន ។

៤-វត្ថុតាងចាប់មកមាន:

ក-ស្រោមសំបុត្រពណ៌លឿងទុំ មានបោះត្រា បិទជិត ចំនួនមួយ មានផ្តិតម្ចាស់ដៃរបស់ជនសង្ស័យ ឈ្មោះ [redacted] វឌ្ឍនា ដោយមានចុះហត្ថលេខារបស់អ្នកចូលរួមសរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀនប្រភេទម្សៅក្រាម ពណ៌សផ្ការួមទម្ងន់សរុប ៨,៣១ (ប្រាំបីក្បៀសសាមសិបមួយ) ក្រាម គប្បីរឹបអូសបំផ្លាញចោល ។

ខ-ជញ្ជីងអេឡិចត្រូនិចសម្រាប់ថ្លឹងគ្រឿងញៀនចំនួនមួយគ្រឿង គប្បីរឹបអូសបំផ្លាញចោល ។

គ-ឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយកំប្លេ និងថង់វិចខ្ចប់គ្រឿងញៀនចំនួនមួយ គប្បីរឹបអូសបំផ្លាញចោល ។

ឃ-កាំបិតផ្តាក់ចំនួន ០២(ពីរ) គប្បីរឹបអូសបំផ្លាញចោល ។

៥-តាមលទ្ធផលកោសលវិច្ច័យគ្រឿងញៀនលេខ ១៤៨៩១/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ ២០១៨ របស់អគ្គលេខាធិការដ្ឋានមន្ទីរពិសោធន៍គ្រឿងញៀនបានបញ្ជាក់ពីលទ្ធផលនៃការធ្វើតេស្តថា សំណាកគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៨,៣០ នៃទម្ងន់សរុប ។ វាស្ថិតនៅក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-គណនាសារធាតុសុទ្ធគ្រឿងញៀនដែលបានដកហូតពីជនជាប់ចោទគឺ:

$$\frac{\text{៨,៣១ ក្រាម} \times \text{៧៨,៣០}}{\text{១០០}} = \text{៦,៥០ ក្រាម ។}$$

៦-ជនជាប់ចោទជនទីតិជនដែលមានសម្បទាគ្រប់ ដែលជាមនុស្សដែលមានការពិចារណាយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួនដែលស្ថិតនៅក្នុង លក្ខខណ្ឌនៃការទទួលខុសត្រូវចំពោះមុខច្បាប់ ។

៧-អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈដែលច្បាប់បានហាមឃាត់ ។

៨-តាមដីកាសន្និដ្ឋានស្តាពរលេខ ៣៣៨៧ អ.ឃ.ភ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ០១ ផ្លូវលំ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ បានសុំឱ្យតុលាការពិនិត្យលើស្ថានសម្រាលទោសដល់ជនជាប់ចោទ គប្បីតុលាការពិចារណា ។

១០-មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ០១ ផ្លូវលំ ភូមិថ្មី សង្កាត់ស្ទឹង មានជ័យ

ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ
ទិនិច្ឆ័យសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] វឌ្ឍនា ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ ពិបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ០១ ផ្លូវលំ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុតាងចាប់យកមាន:

ក-ស្រោមសំបុត្រពណ៌លឿងចុំ មានបោះត្រា បិទជិត ចំនួនមួយ មានផ្ទៃខ្លៅដៃរបស់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា ដោយមានចុះហត្ថលេខារបស់អ្នកចូលរួមសរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀនប្រភេទម្សៅក្រាមពណ៌សផ្ទាទម្ងន់សរុប ៨,៣១ (ប្រាំបីក្បៀសសាមសិបមួយ) ក្រាម **រឹបអូសបំផ្លាញចោល** ។

ខ-ជញ្ជីងអេឡិចត្រូនិចសម្រាប់ថ្លឹងគ្រឿងញៀនចំនួនមួយគ្រឿង **រឹបអូសបំផ្លាញចោល** ។

គ-ឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយកំប្លេ និងថង់វិចខ្ចប់គ្រឿងញៀនចំនួនមួយ **រឹបអូសបំផ្លាញចោល** ។

ឃ-កាំបិតផ្តាក់ចំនួន ០២(ពីរ) **រឹបអូសបំផ្លាញចោល** ។

-សាលក្រមជំនុំជម្រះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៩ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ ។

-បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ព្រះរាជាណាចក្រ
ហត្ថលេខា និងត្រា [redacted]

ចៅក្រម
ហត្ថលេខា និងត្រា [redacted]

បានឃើញ
ចៅក្រមជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ថ្ងៃអង្គារ ១៤រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៩ ។
ព្រះរាជាណាចក្រ

[redacted]

Scanned with CamScanner